# មាតិកា

## I- ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ

១០-០២-២០០០ - ព្រះរាជក្រឹត្យ នស/រកត/០២០០/១០០ តែងតាំងមុខងារ និងតំឡើងឋានន្តរសក្តិ ជូននាយទាហានជាន់ខ្ពស់ កងយោធពលខេមរភូមិន្ទ ៣០៦
១០-០២-២០០០ - ព្រះរាជក្រឹត្យ នស/រកត/០២០០/១០១ តែងតាំងឯកឧត្តម ចំន្ទ សារុន ជាអនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ៣០៩
១១-០២-២០០០ - ព្រះរាជក្រឹត្យ នស/រកត/០២០០/១០២ តែងតាំងឯកឧត្តម ចំន្ទ សារុន ជាទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី ៣១០

## II- រាជរដ្ឋាភិបាល

### ១- អនុក្រឹត្យ

១៥-០២-២០០០ - អនុក្រឹត្យ លេខ ០៦ អនក្រ.បក ស្តីពីការរៀបចំថ្នាក់សិស្សពូកែផ្នែកគណិតវិទ្យា អក្សរសិល្ប៍ខ្មែរ និង រូបវិទ្យា ៣១១
១១-០២-២០០០ - អនុក្រឹត្យ លេខ ៦២ អនក្រ.គត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣១៤
១៥-០២-២០០០ - អនុក្រឹត្យ លេខ ៦៣ អនក្រ.គត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣១៥
១៥-០២-២០០០ -អនុក្រឹត្យ លេខ ៦៤ អនក្រ.គត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣១៦
១៥-០២-២០០០ -អនុក្រឹត្យ លេខ ៦៥ អនក្រ.គត ស្តីពីការជូនមេដាយការងារ ៣១៧
១៥-០២-២០០០ -អនុក្រឹត្យ លេខ ៦៦ អនក្រ.គត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣១៨
១៥-០២-២០០០ -អនុក្រឹត្យ លេខ ៦៧ អនក្រ.គត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣១៩
១៥-០២-២០០០ -អនុក្រឹត្យ លេខ ៦៨ អនក្រ.គត ស្តីពីការជូនមេដាយការងារ ៣២០

### ២-សេចក្តីសំរេច

១០-០២-២០០០ -សេចក្តីសំរេច លេខ ១២ សសរ ស្តីពីការផ្ទេរសិទ្ធិនៃរាជរដ្ឋាភិបាល ៣២១

## III- ការិយាល័យក្រសួង

### ១-ធនាគារជាតិ នៃកម្ពុជា

#### ប្រកាស

៩-០២-២០០០ - ប្រកាស លេខ ធ ៧០០.៣៨ ប្រក ស្តីពីការកំណត់ប្រាក់ងារក្រុមប្រឹក្សាភិបាលនៃធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ ៣២២

៩-០២-២០០០ -ប្រកាស លេខ ធ ៧០០-៣៩ ប្រក ស្តីពីដើមទុនអប្បបរមាសំរាប់ធនាគារពាណិជ្ជ ៣២៥

## ២-ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និងថាមពល

### ប្រកាស

១០-០២-២០០០ - ប្រកាសលេខ ១០២ កកឧ.ប្រក អនុញ្ញាតឲ្យក្រុមហ៊ុន ហ៊្វើលង់ហ្វេរូ (ខេមបូឌា) ពិច ថាយ តំណាងដោយលោក IP WAI KI សញ្ជាតិចិន (ហុងកុង) បង្កើតរោងចក្រ កាត់ដេរ និងចាក់ សំលៀកបំពាក់នាំចេញ ៣២៧

## ៣-ទីស្តីការរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

### ប្រកាស

១០-០១-២០០០ - ប្រកាសលេខ ០២១ ប៉ទ.ប្រក ស្តីពីសេវាភ្ជាប់ និងការថែទាំទូរស័ព្ទ ទូរសារ និង ទូរពុម្ព ក្នុងតំបន់ក្រុងភ្នំពេញ និងតំបន់ខេត្ត-ក្រុង ៣២៩
១១-០២-២០០០ - ប្រកាសលេខ ០២២ ប៉ទ.ប្រក ស្តីពីថ្លៃសេវាទូរគមនាគមន៍ និងរូបភាពទូរទស្សន៍ ប្រើប្រាស់ក្នុងប្រទេស និងអន្តរជាតិ ៣៣៣

# I- ខុទ្ទកាល័យព្រះមហាក្សត្រ

## ព្រះរាជក្រឹត្យ

### ព្រះរាជក្រឹត្យ ជស/រកត/០២០០/១០០

យើង

ព្រះបាទសម្តេចព្រះនរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

***

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/៩៤/០២ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានទ្រង់យល់អនុក្រឹត្យលេខ ៣៧/អនក្រ/គត/ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ ១៩៩៩ ស្តីពីការកែសំរួលរចនាសម្ព័ន្ធចាត់តាំង នៃក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខនស/រកត/០១៩៩/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៩ ស្តីពីការកែសំរួលតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងអគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- យោងតាមសំណើររបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០០

**ត្រាស់បង្គាប់**

មាត្រា ១ ._ ត្រូវបានតែងតាំងមុខងារ និងតម្លើងឋានន្តរសក្តិ ជូននាយទាហានជាន់ខ្ពស់ កងយោធពលខេមរភូមិន្ទនៃអគ្គបញ្ជាការដ្ឋាននៃក្រសួងការពារជាតិ ដូចមានខាងក្រោម ៖

**ក- តែងតាំង និងតម្លើងឋានន្តរសក្តិថ្នាក់ ឧត្តមសេនីយ៍ឯក និងថ្នាក់ឧត្តមនាវីឯក :**

១- ឧត្តមសេនីយ៍ទោ **ជាន់ ខូន** អត្តលេខ ០០០០៥៩ បច្ចុប្បន្ន អនុរដ្ឋលេខាធិការ ក្រសួងការពារជាតិ និងជាមេបញ្ជាការកងហោះដឹកជញ្ជូន ប្រតិភូជាន់ខ្ពស់

២- ឧត្តមសេនីយ៍ទោ **លី ឃីម៉ុន** អត្តលេខ ០០០០៨៣ បច្ចុប្បន្ន អនុរដ្ឋលេខាធិការ ក្រសួងការពារជាតិ

៣- ឧត្តមសេនីយ៍ទោ **ញឹក ហួន** អត្តលេខ ០០០០៥០ បច្ចុប្បន្ន ជានាយរង សេនាធិការចំរុះនៃអគ្គបញ្ជាការដ្ឋាន

៤- ឧត្តមសេនីយ៍ទោ **គៀង សាវុធ** អត្តលេខ ០០០០៣៥ បច្ចុប្បន្ន ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រី

៥- ឧត្តមសេនីយ៍ទោ **ស៊ី ស៊ុនតិច** អត្តលេខ ០០០០៥៦ បច្ចុប្បន្ន ទីប្រឹក្សាក្រសួងការពារជាតិ

៦- ឧត្តមសេនីយ៍ទោ **ជា សារ៉ែន** អត្តលេខ ០០០០៩០ បច្ចុប្បន្ន មេបញ្ជាការរង និងជានាយសេនាធិការកងទ័ពជើងគោក នៃអគ្គបញ្ជាការដ្ឋាន

៧- ឧត្តមសេនីយ៍ទោ **សំរិទ្ធ ឌី** អត្តលេខ ០០០០៣៩ បច្ចុប្បន្ន មេបញ្ជាការរង កងទ័ពជើងគោក នៃអគ្គបញ្ជាការដ្ឋាន

៨- ឧត្តមសេនីយ៍ទោ **ខូវ ឈា** អត្តលេខ ០០០១៥៣ បច្ចុប្បន្ន មេបញ្ជាការរង កងទ័ពជើងគោក នៃអគ្គបញ្ជាការដ្ឋាន

៩- ឧត្តមនាវីទោ **អ៊ុំ សំខាន់** អត្តលេខ ០០០០៥២ បច្ចុប្បន្ន មេបញ្ជាការកងនាវាចរខេមរភូមិន្ទ នៃអគ្គបញ្ជាការដ្ឋាន

**ខ- តម្លើងឋានន្តរសក្តិថ្នាក់ ឧត្តមសេនីយ៍ទោ និងថ្នាក់ ឧត្តមនាវីទោ :**

១- ឧត្តមសេនីយ៍ត្រី **ហួត ឈាង** អត្តលេខ ០០០១៣៦ បច្ចុប្បន្ន នាយសេនាធិការរង និងជានាយការិយាល័យទី៣ កងទ័ពជើងគោក នៃអគ្គបញ្ជាការដ្ឋាន

២- ឧត្តមសេនាវីត្រី **ទៀ វិញ** អត្តលេខ ០០០១៧១ បច្ចុប្បន្ន មេបញ្ជាការរង កងនាវាចរខេមរភូមិន្ទ នៃអគ្គបញ្ជាការដ្ឋាន

**គ- តម្លើងឋានន្តរសក្តិថ្នាក់ ឧត្តមសេនីយ៍ទោ កិត្តិយស :**

១- ឧត្តមសេនីយ៍ត្រី **ឈឹម ឈន** អត្តលេខ ០០០២០៣ បច្ចុប្បន្ន អភិបាលខេត្ត ស្ទឹងត្រែង

ឃ- តែងតាំង និងតម្លើងឋានន្តរសក្តិថ្នាក់ ឧត្តមសេនីយ៍ត្រី :

១- វរសេនីយ៍ឯក ឈុត្រ៉ឹម ឈន អត្តលេខ ០០០២០៣៨៤២៧ បច្ចុប្បន្ន អភិបាលខេត្ត ស្ទឹងត្រែងខុទ្ទកាល័យ នៃអគ្គបញ្ជាការដ្ឋាន

២- វរសេនីយ៍ឯក ខឹម សន អត្តលេខ ០០០៣៦៨ បច្ចុប្បន្ន ជានាយកការិយាល័យទី៥ កងទ័ពជើងគោក នៃអគ្គបញ្ជាការដ្ឋាន

៣- វរសេនីយ៍ឯក ឆាយ គឹមមឹង អត្តលេខ ០០០២៦៨ បច្ចុប្បន្ន ជាជំនួយការឯកឧត្តម យើម ឱមយ៉ុន ទីប្រឹក្សារាជរដ្ឋាភិបាល

៤- វរសេនីយ៍ឯក សេ សាផន បច្ចុប្បន្ន ជានាយករង នាយកដ្ឋាននយោបាយនិងផែនការ នៃក្រសួងការពារជាតិ

មាត្រា ២ ._ នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសម្រេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣._ ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

រាជធានីភ្នំពេញ, ថ្ងៃទី៣០ ខែកុម្ភៈ ឆ្នាំ ២០០០

ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាសព្វបង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

បានជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី

សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ

ព្រះហស្តលេខា និង ហត្ថលេខា

អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ សិរីរ័ត្ន ទៀ បាញ់

# ព្រះរាជក្រឹត្យ ជស/រកត/០២០០/១០១

យើង

ព្រះបាទសម្តេចព្រះនរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

***

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/៩៤/០២ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខនស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០០០

## ត្រាស់បង្គាប់

**មាត្រា ១ .-** ត្រូវបានតែងតាំងឯកឧត្តម ច័ន្ទ សារុន ជាអនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ២ .-** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣.-** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

រាជធានីភ្នំពេញ, ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ ២០០០

ក្នុងព្រះបរមនាម និងតាមព្រះរាជព្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

★★★

# ព្រះរាជក្រឹត្យ ជស/រកត/០២០០/១០២

យើង

ព្រះបាទសម្តេចព្រះនរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

***

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/៩៤/០២ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខនស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០០០

## ត្រាស់បង្គាប់

**មាត្រា ១ .-** ត្រូវបានតែងតាំងឯកឧត្តម ចំន្ទ សារុន ជាទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកការងារព្រៃឈើ បន្ថែមលើមុខងារបច្ចុប្បន្ន មានឋានៈស្មើ រដ្ឋលេខាធិការ ។

**មាត្រា ២ .-** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣.-** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

រាជធានីភ្នំពេញ, ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ ២០០០

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា

ជា ស៊ីម

# II- រាជរដ្ឋាភិបាល

## ១- អនុក្រឹត្យ

### អនុក្រឹត្យលេខ ០៦ អនក្រ.បក

### ស្តីពី

### ការរៀបចំថ្នាក់សិស្សពូកែផ្នែក គណិតវិទ្យា អក្សរសិល្ប៍ខ្មែរ និង រូបវិទ្យា

***

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/៩៤/០២ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- យោងអនុក្រឹត្យលេខ ២៨ អនក្រ.បក ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំថ្នាក់សិស្សពូកែ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

### សំរេច

**មាត្រា ១ .-** អនុញ្ញាតឲ្យក្រសួង អប់រំ យុវជន និងកីឡា បង្កើតថ្នាក់សិស្សពូកែផ្នែកគណិតវិទ្យា អក្សរសិល្ប៍ខ្មែរ និងរូបវិទ្យាតាមកំរិតថ្នាក់នីមួយៗ នៅមធ្យមសិក្សាដើម្បីពង្រឹងគុណភាពអប់រំនៃមុខ វិជ្ជាមូលដ្ឋានលោនដល់ចលនាប្រឡងប្រណាំងរៀនសូត្ររបស់សិស្សានុសិស្សអោយកាន់តែល្អប្រសើរ សំដៅអភិវឌ្ឍធនធានមនុស្ស ប្រកបដោយសីលធម៌និងចំណេះដឹងខ្ពង់ខ្ពស់ ។

មាត្រា ២._ -វិទ្យាល័យ ឬអនុវិទ្យាល័យ អាចរៀបចំថ្នាក់សិស្សពូកែផ្នែកគណិតវិទ្យា អក្សរសិល្ប៍ខ្មែរ និងរូបវិទ្យា តាមគំនិតច្នៃប្រឌិតរបស់ខ្លួន ។

មាត្រា ៣._ -ការសំរេចអោយឡើងថ្នាក់សិស្សពូកែខ្ពស់ជាងបន្ទប់បន្ទាប់ ឬ ការបញ្ជូនអោយទៅរៀនថ្នាក់ធម្មតាវិញ ជាសមត្ថកិច្ចផ្ទាល់របស់គ្រឹះស្ថានមធ្យមសិក្សា ឈរលើលក្ខណៈវិនិច្ឆ័យមួយ ដែលជាគំនិតផ្តួចផ្តើមរបស់គណៈគ្រប់គ្រងសាលារៀន ។

មាត្រា ៤._ -គ្រប់ខេត្ត-ក្រុង និងគ្រប់គ្រឹះស្ថានមធ្យមសិក្សាក្រោមឱវាទផ្ទាល់ក្រសួងអប់រំ យុវជន និងកីឡា ត្រូវចាត់ចែងធ្វើការប្រឡងជ្រើសរើសសិស្សពូកែផ្នែកគណិតវិទ្យា អក្សរសិល្ប៍ខ្មែរ និងរូបវិទ្យា សំរាប់ថ្នាក់បញ្ចប់មធ្យមសិក្សាបឋមភូមិ និងទុតិយភូមិ ។

មាត្រា ៥._ -ក្រសួងអប់រំ យុវជន និងកីឡា នឹងរៀបចំធ្វើការប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេសផ្នែកគណិតវិទ្យា អក្សរសិល្ប៍ខ្មែរ និងរូបវិទ្យាសំរាប់ថ្នាក់បញ្ចប់មធ្យមសិក្សា បឋមភូមិ និងថ្នាក់បញ្ចប់មធ្យមសិក្សាទុតិយភូមិ ក្នុងចំណោមបេក្ខជនសិស្សពូកែដែល ខេត្ត-ក្រុងបានធ្វើការប្រឡងជ្រើសរើសរួចហើយ ។

មាត្រា ៦._ -ការប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេស នឹងប្រព្រឹត្តទៅនៅខេត្ត-ក្រុងណាមួយ តាមវិញ្ញាសាសរសេរ និងផ្ទាល់មាត់ ។ ប្រធានវិញ្ញាសាចេញដោយក្រសួងអប់រំ យុវជន និងកីឡា ដោយផ្អែកតាមកម្មវិធីសិក្សាពីថ្នាក់ទី៧ ដល់ថ្នាក់ទី៩ សំរាប់សិស្សថ្នាក់ទី៩ និងពីថ្នាក់ទី៧ ដល់ថ្នាក់ទី១២ សំរាប់សិស្សថ្នាក់ទី១២ ។

មាត្រា ៧._ -បេក្ខជនសិស្សពូកែទូទាំងប្រទេស អាចជ្រើសរើសយកបានតែមួយមុខវិជ្ជាប៉ុណ្ណោះ ។ បេក្ខជនម្នាក់ៗ ត្រូវធ្វើការប្រឡងជាបីពេល លើមុខវិជ្ជាដែលសាមីខ្លួនបានជ្រើសរើសពីរពេល និងលើមុខវិជ្ជាវប្បធម៌ទូទៅមួយពេល ។

មាត្រា ៨._ -នឹងត្រូវប្រកាសថា ជាជ័យលាភី ក្នុងការប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេស បេក្ខជន ដែលបានពិន្ទុចាប់ពីមធ្យមឡើងទៅ លើមុខវិជ្ជាវប្បធម៌ទូទៅ លើមុខវិជ្ជាឯកទេស និងបានពិន្ទុលើសគេចំនួន ១០នាក់ ដំបូងតាមមុខវិជ្ជាឯកទេស និងតាមកំរិតថ្នាក់ ។ ជ័យលាភីម្នាក់ៗ ត្រូវបានទទួលរង្វាន់ពីរដ្ឋទៅតាមចំណាត់ថ្នាក់ និងសំភារៈផ្សេងៗ ដូចខាងក្រោម :

១- ប្រកាសទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡាមួយច្បាប់

២- មេដាយមួយគ្រឿង (ពីលេខ ១ ដល់លេខ ៣)

៣- វិញ្ញាបនប័ត្រសិស្សពូកែទូទាំងប្រទេសមួយសន្លឹក

៤- ប្រាក់រង្វាន់

| | | | |
|---|---|---|---|
| លេខ ១ | ៨០០.០០០ រ | លេខ ៦ | ៦៥០.០០០ រ |
| លេខ ២ | ៧៧០.០០០ រ | លេខ ៧ | ៦២០.០០០ រ |
| លេខ ៣ | ៧៥០.០០០ រ | លេខ ៨ | ៥៩០.០០០ រ |
| លេខ ៤ | ៧១០.០០០ រ | លេខ ៩ | ៥៦០.០០០ រ |
| លេខ ៥ | ៦៨០.០០០ រ | លេខ ១០ | ៥៣០.០០០ រ |

៥- ប្រាក់រង្វាន់ ឬវត្ថុផ្សេងៗពិសេសប្បុរសជន

មាត្រា ៩._ -ក្រសួងអប់រំ យុវជន និងកីឡា មានភារកិច្ចរៀបចំពិធីបើកការប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេស និងរៀបចំពិធីចែករង្វាន់ជូនជ័យលាភីសិស្សពូកែទូទាំងប្រទេសផ្នែកគណិតវិទ្យា អក្សរសិល្ប៍ខ្មែរ និងរូបវិទ្យា អោយបានសមរម្យ ។

មាត្រា ១០._ -គណៈមេប្រយោគប្រឡងសិស្សពូកែទូទាំងប្រទេស ត្រូវធ្វើការ និងទទួលប្រាក់ឧបត្ថម្ភតាមរបបម៉ោងបន្ថែមដោយគិតក្នុងមួយថ្ងៃធ្វើការ ៦ម៉ោងបន្ថែម ហើយប្រាក់កំរៃមួយម៉ោង ស្មើនឹងប្រាក់កំរៃនៃមួយម៉ោងបន្ថែមរបស់គ្រូបង្រៀនមធ្យមសិក្សាទុតិយភូមិ ។ ការតាំងគណៈមេប្រយោគប្រឡងជ្រើសរើសសិស្សពូកែទូទាំងប្រទេស ជាសមត្ថកិច្ចរបស់ ក្រសួងអប់រំ យុវជន និងកីឡា ។

មាត្រា ១១ ._ -សំភារៈចាំបាច់ផ្សេងៗ ថវិកាប្រឡង សោហ៊ុយរៀបចំពិធីបើកការប្រឡង និងពិធីចែករង្វាន់ សោហ៊ុយធ្វើដំណើរ ស្នាក់នៅហូបចុក សំរាប់ដំណើរការប្រឡងសិស្សពូកែទូទាំងប្រទេស និងដំណើរកំសាន្តរបស់យុវជន ជាបន្ទុករបស់រាជរដ្ឋាភិបាល ។ សោហ៊ុយផ្សេងៗ នឹងមានចែងក្នុងអត្ថបទមួយ ។

មាត្រា ១២._ -អនុក្រឹត្យលេខ ២៨ អនក្រ.ប្រក ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ១៩៩៨ ស្ដីពីការរៀបចំថ្នាក់សិស្សពូកែផ្នែក គណិតវិទ្យា និងអក្សរសិល្ប៍ខ្មែរ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ១៣._ -រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួង-ស្ថាប័នពាក់ព័ន្ធ មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ហ៊ុន សែន

★★★

# អនុក្រឹត្យលេខ ៦២ អនក្រ.តត
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/៩៤/០២ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្ត តាកែវ

## សំរេច

**មាត្រា ១ .-** ត្រូវបានប្រគល់ មេដាយមាសស្ថាបនាជាតិ ជូនសប្បុរសជនខ្មែរចំនួន ១១រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមជួយកសាងសមិទ្ធផលផ្សេងៗ នៅក្នុងវត្តចារ ឃុំចារ ស្រុកព្រៃកប្បាស ខេត្តតាកែវ ដូចជា ព្រះវិហារ កុដិ សាលាធម្មសភា អាគារសិក្សា ក្លោងទ្វារ របងស្រះទឹក ដូចមានរាយព្រះនាម និងនាមខាងក្រោមនេះ :

១- ព្រះតេជគុណ ឆិត្ស នៅ ព្រះវិន័យធរ អនុគណស្រុកព្រៃកប្បាស និង ជាព្រះចៅអធិការវត្ត ចារ ទឹកប្រាក់ជាង ១០០ លានរៀល

២- ឯកឧត្តម ហេង ឌូ និងលោកជំទាវ ឡុង ផល្លី ទឹកប្រាក់ចំនួន ១០.០០០ USD

៣- លោក ញឹម សេងឈោ និងលោកស្រី ស៊ុខ ផាលី នៅសហរដ្ឋអាមេរិក ទឹកប្រាក់ចំនួន ៤២.០០០ USD

៤- ឧបាសិកា ស៊ុខ ខិនហួយ នៅសហរដ្ឋអាមេរិក ទឹកប្រាក់ចំនួន ២៦.០០០ USD

៥- ឧបាសិកា គាំង សេង និងបុត្រ នៅរាជធានីភ្នំពេញ ទឹកប្រាក់ចំនួន ២៦.០០០ USD

៦- លោកស្រី ឡាយ សំអន និងបុត្រ នៅរាជធានីភ្នំពេញទឹកប្រាក់ចំនួន ២៥.០០០ USD

៧- លោក ឈៅ ឆួន និងលោកស្រី មាស ស៊ីថន នៅរាជធានីភ្នំពេញ ទឹកប្រាក់ចំនួន ២៥.០០០ USD

៨- លោក ពៅ ញ៉េម និងអ្នកស្រី ពុយ នី នៅសហរដ្ឋអាមេរិក

ទឹកប្រាក់ចំនួន ២០.០០០ USD

៩- លោក ឈាន ហ៊ី និងអ្នកស្រី ឡាច ឆយ អតីតអភិបាលស្រុកព្រៃកប្បាស

ទឹកប្រាក់ចំនួន ១៥.០០០ USD

១០- លោកស្រី ធីក ស្រ៊ន និងបុត្រ នៅសហរដ្ឋអាមេរិក ទឹកប្រាក់ចំនួន ១៥.០០០ USD

១១- លោក ម៉ូ ហោនាង និងអ្នកស្រី ង៉ុង រ៉ិន្ធារី នៅសហរដ្ឋអាមេរិក

ទឹកប្រាក់ចំនួន ១៥.០០០ USD

**មាត្រា ២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី និងអភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០០

នាយករដ្ឋមន្ត្រី

បាត់លេខា និង ត្រា

ហ៊ុន សែន

★★★

**អនុក្រឹត្យលេខ ៦៣ អនក្រ.តត**

**ស្ដីពីការជូនមេដាយស្ថាបនាជាតិ**

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/៩៤/០២ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្ដីពីការប្រកាសប្រើគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា ១ ._ ត្រូវបានប្រគល់ មេដាយមាសស្ថាបនាជាតិ ជូនសមាគម SINGONG SU ប្រទេសជប៉ុន ដែលបានជួយកសាងអាគារសិក្សា ០២ ខ្នងមាន ០៨ បន្ទប់ ដោយមានបំពាក់សម្ភារៈសិក្សាគ្រប់គ្រាន់ ជូនសាលាបឋមសិក្សា IROHA ក្រុងតាខ្មៅ ខេត្តកណ្តាល ចំណាយអស់ថវិកាសរុបចំនួន ៤៥.០០០ ដុល្លារអាមេរិក ។

មាត្រា ២._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា និងអភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០០០

នាយករដ្ឋមន្ត្រី

បាត្តលេខា និង ត្រា

ហ៊ុន សែន

★★★

## អនុក្រឹត្យលេខ ៦៤ អនក្រ.តត

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

***

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/៩៤/០២ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកំពង់ឆ្នាំង

សម្រេច

មាត្រា ១ ._ ត្រូវបានប្រគល់ មេដាយមាសស្ថាបនាជាតិ ជូនលោក ជីដូន ចំរើន និងលោកស្រី ស៊ើ លាងហួ សប្បុរសជនខ្មែរ នៅសហរដ្ឋអាមេរិក ដែលបានជួយកសាងអាគារសិក្សា ០១ខ្នង មាន ០៥បន្ទប់

នៅសាលាបឋមសិក្សាសម្តេចមុន្នី ឃុំខ្នុរវ៉ែង ស្រុកពេរិបូរណ៍ ខេត្តកំពង់ឆ្នាំង ចំណាយទឹកប្រាក់សរុប ចំនួន ២៤.៨០០ ដុល្លារអាមេរិក ។

មាត្រា ២._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងអភិបាលខេត្តកំពង់ឆ្នាំង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០០០

នាយករដ្ឋមន្ត្រី

បានហត្ថលេខា និង ត្រា

ហ៊ុន សែន

★★★

## អនុក្រឹត្យលេខ ៦៥ អនក្រ.តត

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

***

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/៩៤/០២ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់នាយកខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

### សំរេច

មាត្រា ១ ._ ត្រូវបានប្រគល់ **មេដាយមាសការងារ** ជូននាយទាហាន បស្តូរ នៃកងឯកភាពអង្គរក្សសម្តេច **ហ៊ុន សែន** ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ច ដូចមានរាយនាមខាងក្រោមនេះ ៖

១- លោកឧត្តមសេនីយ៍ត្រី **ហ៊ីង ប៊ុនហៀង** មេបញ្ជាការកងឯកភាពអង្គរក្ស

២- លោកឧត្តមសេនីយ៍ត្រី **ហ៊ុយ ពិសិដ្ឋ** មេបញ្ជាការកងឯកភាពអង្គរក្ស

៣- លោកវរសេនីយ៍ឯក **សុខ ចារុណ** មេបញ្ជាការរងកងឯកភាពអង្គរក្ស

៤- លោកវរសេនីយ៍ឯក ចៅ តុល មេបញ្ជាការរងកងឯកភាពអង្គរក្ស

៥- លោកវរសេនីយ៍ឯក ដៀង សារុន មេបញ្ជាការរងនិងជានាយសេនាធិការ កងឯកភាពអង្គរក្ស

៦- លោកវរសេនីយ៍ឯក សុខ សុខៈ អង្គរក្សផ្ទាល់

៧- លោកវរសេនីយ៍ឯក ហេង សាទឿន អង្គរក្សផ្ទាល់

៨- លោកវរសេនីយ៍ត្រី ឈុប ឈុំ នាយសេនាធិការវរសេនាតូចលេខ ៤

៩- លោកវរសេនីយ៍ត្រី ខិម ម៉ាន់ នាយសេនាធិការវរសេនាតូចលេខ ៥

មាត្រា ២._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ហ៊ុន សែន

★★★

## អនុក្រឹត្យលេខ ៦៦ អនក្រ.បក
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/៩៤/០២ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

**សំរេច**

មាត្រា ១ ._ ត្រូវបានប្រគល់ **មេដាយមាសស្ថាបនាជាតិ** ជូនសមាគម SAKAIMINAMI LIONS CLUB ប្រទេសជប៉ុន ដែលបានជួយកសាងអាគារសិក្សា ០១ខ្នង មាន ០៥បន្ទប់ ជូនសាលាបឋមសិក្សាព្រួចស៊េច ក្នុងស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ចំណាយអស់ថវិកាចំនួន ២៥.០០០ ដុល្លារអាមេរិក ។

មាត្រា ២._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**ហ៊ុន សែន**

★★★

## អនុក្រឹត្យលេខ ៦៧ អនក្រ.គត

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/៩៤/០២ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សំរេច

**មាត្រា ១ .-** ត្រូវបានប្រគល់ មេដាយមាសស្ថាបនាជាតិ ជូនឯកឧត្តម កែវ សាផល អនុរដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ដែលបានជួយកសាងអាគារសិក្សា ០២ខ្នង មាន ០៧បន្ទប់ នៅក្នុងសាលាបឋមសិក្សា កែវម៉ុ ឌួនមុត ប៉ែកចាន ក្នុងស្រុកស្វាយទាប ខេត្តស្វាយរៀង ចំណាយអស់ថវិកាសរុបចំនួន ១៨.០០០ ដុល្លារ អាមេរិក ។

**មាត្រា ២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាលខេត្តស្វាយរៀង ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០០០

នាយករដ្ឋមន្ត្រី

បណ្ឌិតសេនា និង ត្រា

ហ៊ុន សែន

★★★

## អនុក្រឹត្យលេខ ៦៨ អនក្រ.គត

## ស្តីពីការជូនមេដាយការងារ

***

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/៩៤/០២ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ

សំរេច

**មាត្រា ១.-** ត្រូវបានប្រគល់ មេដាយសិរិទ្ធ ការងារ ជូននាយទាហាន ០២រូប នៃអធិការកិច្ចកងទ័ពជើងគោក ដែលមានស្នាដៃល្អ ក្នុងការចុះដោះស្រាយបាតុភាពទំនាស់ដីធ្លី រវាងប្រជាពលរដ្ឋ នៅស្រុកបវេល ខេត្តបាត់ដំបង ជាមួយទាហាននៃកងពលធំលេខ ៦ ដូចមានរាយនាមខាងក្រោមនេះ :

១- លោក វរសេនីយ៍ឯក ម៉ៅ ញ៉ី នាយរងអធិការកិច្ចកងទ័ពជើងគោក

២- លោក វរសេនីយ៍ត្រី អ៊ិត នរិន្ទ នាយរងផ្នែកយោធភូមិភាគនៃអធិការកិច្ចកងទ័ពជើងគោក

**មាត្រា ២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងអគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ហ៊ុន សែន

★★★

## ២-សេចក្តីសំរេច

រាជធានីភ្នំពេញ, ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០០០

### សេចក្តីសំរេចលេខ ១២ សសរ.

### ស្តីពីការផ្ទេរសិទ្ធិ នៃរាជរដ្ឋាភិបាលកម្ពុជា

***

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការងារចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជា

សម្រេច

ប្រការ ១ : ផ្ទេរសិទ្ធិជូនឯកឧត្ដម ស ខេង ឧបនាយករដ្ឋមន្ត្រី និងជាសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជានាយករដ្ឋមន្ត្រីស្ដីទី នៃរាជរដ្ឋាភិបាលកម្ពុជា ជំនួសសម្ដេចនាយករដ្ឋមន្ត្រី ដែលត្រូវអញ្ជើញទៅចូលរួមក្នុងកិច្ចប្រជុំ «ជំនួបកំពូលអាស៊ាន អង្គការសហប្រជាជាតិ ស្ដីពីពាណិជ្ជកម្ម និងការអភិវឌ្ឍន៍ លើកទី១០» នៅទីក្រុងបាងកក នៃព្រះរាជាណាចក្រថៃឡង់ដ៍ ចាប់ពីថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០០ រហូតដល់សម្ដេចនាយករដ្ឋមន្ត្រី អញ្ជើញវិលត្រឡប់មកកាន់មាតុប្រទេសវិញ ។

ប្រការ ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័ន ប្រតិភូរាជរដ្ឋាភិបាល អភិបាលគ្រប់ខេត្ត-ក្រុង និងឯកឧត្ដម ស ខេង ត្រូវអនុវត្ត សេចក្ដីសម្រេចនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ហ៊ុន សែន

★★★

# III- ការងារបណ្ដាក្រសួង

## ១- ធនាគារជាតិនៃកម្ពុជា

### ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី ១០ ខែ មករា ឆ្នាំ

### ប្រកាសលេខ ធ ៧០០-៣៨ ប្រក

ស្ដីពី

### សាច់ប្រាក់ងាយស្រួលរបស់ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ

***

### ទេសាភិបាល ធនាគារជាតិនៃកម្ពុជា

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃធនាគារជាតិនៃកម្ពុជា

- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣៩៨/៨៥ ចុះថ្ងៃទី ១០ ខែ មិនា ឆ្នាំ ១៩៩៨ ស្ដីពី ការតែងតាំង ឯកឧត្ដម **ជា ចាន់តូ** ជាអគ្គទេសាភិបាលនៃធនាគារជាតិនៃកម្ពុជា
- យោងតាមសំណើរបស់នាយកដ្ឋានត្រួតពិនិត្យ

**សំរេច**

**ប្រការ ១ :**

ធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុតទៅនេះហៅថា "ធនាគារ" ត្រូវអនុវត្តអោយបាន តាមវិធានគ្រប់គ្រងក្នុងគោលបំណងធានាសាច់ប្រាក់ងាយស្រួលរបស់ខ្លួន ដូចមានចែងក្នុងប្រការ បន្តបន្ទាប់ខាងក្រោម ។

**ប្រការ ២ :**

ធនាគារត្រូវតែរក្សានូវអនុបាតសាច់ប្រាក់ងាយស្រួលអប្បបរមាយ៉ាងហោចណាស់ ៥០% ដែលត្រូវគណនានិងធ្វើរបាយការណ៍ទៅធនាគារជាតិនៃកម្ពុជា ប្រចាំខែរបស់ខ្លួន ។

**ប្រការ ៣ :**

ភាគយកនៃអនុបាតសាច់ប្រាក់ងាយស្រួលរួមមាន ៖

១- សមតុល្យសាច់ប្រាក់ដូចមានកំណត់ក្នុងប្រការ ៥ នៃប្រកាសនេះ នៅពេលសមតុល្យ នេះតំណាងអោយស្ថានភាពនៃអ្នកអោយខ្ចី

២- ចំណែកនៃការអោយខ្ចីនៅសល់រយៈពេលមិនលើសពី១ខែ (លើកលែងតែឥណទាន ចំពោះអតិថិជនដោយគ្មានកាលវសាន ដូចជាឥណទានលើសសមតុល្យ)

៣- ប័ណ្ណរតនាគារក្នុងរយៈពេលនៅសល់មិនលើសពី ១ ខែ ។

**ប្រការ ៤ :**

ភាគបែងនៃអនុបាតសាច់ប្រាក់ងាយស្រួលរួមមាន ៖

១- សមតុល្យសាច់ប្រាក់ដូចមានកំណត់ក្នុងប្រការ ៥ នៃប្រកាសនេះនៅពេលសមតុល្យ នេះតំណាងអោយស្ថានភាពអ្នកខ្ចី

២- ៨០ ភាគរយនៃចំណែកប្រាក់បញ្ញើមានកាលកំណត់ និងវិញ្ញាបនប័ត្រប្រាក់បញ្ញើ ដែលមានរយៈពេលនៅសល់មិនលើសពី ១ ខែ

៣- ៥០ ភាគរយនៃចំណែកប្រាក់បញ្ញើមានកាលកំណត់ និងវិញ្ញាបនប័ត្រប្រាក់បញ្ញើ ដែលមានរយៈពេលនៅសល់លើសពី ១ ខែ

៤- ៥០ ភាគរយនៃប្រាក់បញ្ញើសន្សំ

៥- ៦០ ភាគរយនៃប្រាក់បញ្ញើគ្មានកាលកំណត់ ។

**ប្រការ ៥ :**

សមតុល្យសាច់ប្រាក់ស្មើនឹងផលសងរវាងសរុបខ្ទង់ឥណពន្ធ ជាមួយសរុបខ្ទង់ឥណទាន ដូចមានរៀបរាប់ខាងក្រោម ៖

១- ខ្ទង់ឥណពន្ធ

ក- សាច់ប្រាក់ និងមាស

ខ- ប្រាក់បញ្ញើនៅធនាគារជាតិនៃកម្ពុជា

គ- ប្រាក់បញ្ញើនៅធនាគារផ្សេងៗ

ឃ- ចំណែកនៃការអោយខ្ចីទៅធនាគារនិងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងៗ ក្នុងរយៈពេលនៅសល់មិនលើសពី ១ខែ ( លើកលែងតែឥណទានដែលគ្មានកំណត់កាលវសាន) ។

២- ខ្ទង់ឥណទាន

- សមតុល្យឥណទានវិបារូបលើគណនីប្រាក់បញ្ញើគ្មានកាលកំណត់ដែលបានបើកនៅធនាគារជាតិនៃកម្ពុជានៅធនាគារ ឬនៅគ្រឹះស្ថានហិរញ្ញវត្ថុផ្សេង
- ប្រាក់ខ្ចីពីធនាគារជាតិនៃកម្ពុជា និងពីធនាគារផ្សេងដោយមានរយៈពេលនៅសល់មិនលើសពី ១ ខែ ។

សមតុល្យសាច់ប្រាក់ត្រូវបានចាត់ទុកថា តំណាងអោយស្ថានភាពអ្នកអោយខ្ចី នៅពេលណាសរុបខ្ទង់ឥណពន្ធកើនលើសសរុបខ្ទង់ឥណទាន ។ សមតុល្យសាច់ប្រាក់ត្រូវចាត់ទុកថាតំណាងអោយស្ថានភាពអ្នកខ្ចី នៅពេលណាសរុបខ្ទង់ឥណទានកើនលើសសរុបខ្ទង់ឥណពន្ធ ។

**ប្រការ ៦ :**

នៅរៀងរាល់ពេល ធនាគារត្រូវមានអនុបាតសាច់ប្រាក់ងាយស្រួលយ៉ាងតិចបំផុត ១០០ ភាគរយ ។

**ប្រការ ៧ :**

ធនាគារត្រូវធ្វើប្រតិវេទន៍ប្រចាំខែ ពីអនុបាតសាច់ប្រាក់ងាយស្រួលរបស់ខ្លួន ស្របតាមគំរូ ដែលធនាគារជាតិនៃកម្ពុជាបានដាក់ចេញ ។

ប្រការ ៨ :

រាល់លិខិតបទដ្ឋានទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៩ :

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន អង្គភាព គ្រប់គ្រឹះស្ថានធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ នៅក្រោមឱវាទ និងក្រោមអាណាព្យាបាល ធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងខ្លួន ។

ប្រការ ១០ :

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែកុម្ភៈ ឆ្នាំ២០០០

ទេសាភិបាល

ហត្ថលេខា និងត្រា

**ជា ចាន់តូ**

★★★

រាជធានីភ្នំពេញ, ថ្ងៃទី ០៩ ខែកុម្ភៈ ឆ្នាំ២០០០

## ប្រកាសលេខ ធ ៧០០-៣៩ ប្រក
## ស្តីពី ដើមទុនអប្បបរមាសំរាប់ធនាគារពាណិជ្ជកម្ម

***

**ទេសាភិបាល ធនាគារជាតិនៃកម្ពុជា**

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣៩៨/៨៥ ចុះថ្ងៃទី ១០ ខែ មិនា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំង ឯកឧត្តម **ជា ចាន់តូ** ជាអគ្គទេសាភិបាលនៃធនាគារជាតិនៃកម្ពុជា

- យោងតាមសំណើរបស់នាយកដ្ឋានត្រួតពិនិត្យ

**សំរេច**

ប្រការ ១ :

មុនពេលទទួលបានអាជ្ញាប័ណ្ណ ធនាគារពាណិជ្ជដែលបានបង្កើតឡើងក្រោមទំរង់ជាក្រុម-ហ៊ុននៃច្បាប់ក្នុងស្រុក ត្រូវមានដើមទុនអប្បបរមាដែលបានបង់ជំរះយ៉ាងតិចបំផុតស្មើ ហាសិប-ពាន់លានរៀល (៥០.០០០.០០០.០០០ រៀល) ។

ប្រការ ២ :

មុនពេលទទួលបានអាជ្ញាប័ណ្ណ សាខាធនាគារបរទេសត្រូវមានដើមទុនដែលបង់ជំរះយ៉ាង តិចបំផុតស្មើនឹងដើមទុនអប្បបរមារបស់ធនាគារដែលបានបង្កើតឡើងក្រោមទំរង់ជាក្រុមហ៊ុននៃច្បាប់ក្នុងស្រុក ដូចមានចែងក្នុងប្រការ ១ ខាងលើ ។

ប្រការ ៣ :

ធនាគារពាណិជ្ជដែលបានធ្វើប្រតិបត្តិការនៅកម្ពុជាមុនដំណាច់ឆ្នាំ ១៩៩៧ ត្រូវបំពេញដើមទុនអោយបានគ្រប់តាមកំរិតដើមទុនអប្បបរមាក្នុងប្រការ១ នៃប្រកាសនេះយ៉ាងយឺតបំផុតរហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០០១ ។

ប៉ុន្តែ ធនាគារជាតិនៃកម្ពុជានឹងផ្តល់ការអនុគ្រោះនេះអោយរហូតដល់កាលបរិច្ឆេទខាងលើចំពោះតែធនាគារពាណិជ្ជណាដែលបានបង្ហាញថាមានស្ថានភាពហិរញ្ញវត្ថុល្អប្រសើរប៉ុណ្ណោះ ។

ប្រការ ៤ :

ដើម្បីជាភស្តុតាងបញ្ជាក់ថា ទ្រព្យសកម្ម បន្ទាប់ពីដកចេញនូវការខាត និងនូវទ្រព្យសកម្មអរូបិយដែលពាក់ព័ន្ធកើនលើសពីទ្រព្យអកម្ម ចំពោះតតិយជនតាមចំនួនទឹកប្រាក់យ៉ាងតិចស្មើនឹងដើមទុនអប្បបរមា ធនាគារត្រូវស្រាវជ្រាវកឲ្យឃើញជាអចិន្ត្រៃយ៍ថា មូលនិធិផ្ទាល់សុទ្ធមូលដ្ឋានដូចបានពណ៌នាស្របតាមបញ្ញត្តិនៃប្រកាសស្តីពីការគណនាមូលនិធិផ្ទាល់សុទ្ធ យ៉ាងតិចបំផុតត្រូវស្មើនឹងដើមទុនអប្បបរមា ។

ប្រការ ៥ :

រាល់លិខិតបទដ្ឋានទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីស្មារតីនៃប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

ប្រការ ៦ :

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គបេឡា អគ្គាធិការដ្ឋាន គ្រប់នាយកដ្ឋាន អង្គភាពគ្រប់គ្រឹះស្ថានធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុ នៅក្រោមឱវាទនិងក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ។

ប្រការ ៧ :

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

អភិបាល

ហត្ថលេខា និងត្រា

ជា ចាន់តូ

★★★

## ២- និស្តិការរដ្ឋមន្ត្រីក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល

## ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ ២០០០

### ប្រកាសលេខ ១០២ កកឧ.ប្រក

***

### រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ របស់ព្រះករុណា ព្រះបាទសម្តេចនរោត្តមសីហនុ ព្រះចៅក្រុងកម្ពុជាធិបតី ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានឃើញលិខិតលេខ ២៧៣៣/៩៩ គ.វ.ក ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ១៩៩៩ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញលិខិតលេខ ៩៧/២០០០ ប.ស្ថ ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០០០ របស់ក្រសួងបរិស្ថាន

- បានឃើញលិខិតលេខ ៥០៧ ធត.ស៍ ចុះថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០០០ របស់សាលាក្រុងភ្នំពេញ ស្ដីពីការអនុញ្ញាតឲ្យបើកទីតាំងរោងចក្រកាត់ដេរ
- យោងពាក្យស្នើរបស់ក្រុមហ៊ុន ហ៊្វុលវែលយូ (ខេមបូឌា)តិចថាយ ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០០០

**សំរេច**

**ប្រការ ១ :** អនុញ្ញាតឲ្យក្រុមហ៊ុន ហ៊្វុលវែលយូ (ខេមបូឌា) តិចថាយ " FULL VALUE (CAMBODIA) TEXTILES LTD." តំណាងដោយលោក IP WAI KI សញ្ជាតិចិន (ហុងកុង) ភេទប្រុស អាយុ៥៣ឆ្នាំ កាន់លិខិតឆ្លងដែនលេខ H00292471 ចុះថ្ងៃទី ០២-១២-១៩៩៧ បង្កើត "រោងចក្រកាត់ដេរនិងចាក់សំលៀកបំពាក់នាំចេញ ដែលមានផ្លាកឈ្មោះថា "ហ៊្វុល វែលយូ (ខេមបូឌា) តិចថាយ (រោងចក្រកាត់ដេរនិងចាក់សំលៀកបំពាក់)" ដែលមានទីតាំងស្ថិតនៅ អាគារ A នៃប្លង់សាងសង់លេខ ៨១៧ សជ/៩៨ ចុះថ្ងៃទី០២-១២-១៩៩៨ តាមបណ្ដោយផ្លូវពីស្ថានីយវិទ្យុស្ទឹងមានជ័យទៅចោមចៅ ភូមិត្រពាំងថ្លឹង សង្កាត់ចោមចៅ ខ័ណ្ឌដង្កោ រាជធានីភ្នំពេញ ។

**ប្រការ ២ :** ការរៀបចំអាគារនិងគ្រឿងចក្រ ក្រុមហ៊ុនត្រូវធ្វើទៅតាមប្លង់ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឲ្យបានសំរេចក្នុងរយៈពេល ០៦ខែ ដោយរាប់បញ្ចូលទាំងរយៈពេលដំណើការសាកល្បងផង ។

**ប្រការ ៣ :** រោងចក្រនេះត្រូវបានអនុញ្ញាតឲ្យ "កាត់ដេរនិងចាក់សំលៀកបំពាក់" ទៅតាមគំរូដែលតំកល់ទុក ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែ អំពីស្ថានភាពផលិតកម្មរបស់រោងចក្រ ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

**ប្រការ ៤ :** ក្រុមហ៊ុនត្រូវលើកបង្ហាញ "ផ្លាកឈ្មោះរោងចក្រ" របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាងនិងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

**ប្រការ ៥ :** រាល់ការនាំចេញផលិតផលសំរេច ក្រុមហ៊ុនត្រូវសុំវិញ្ញាបនប័ត្របញ្ជាក់ផលិតកម្ម ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

**ប្រការ ៦ :** ក្រុមហ៊ុនត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និងគុណភាពផលិតផលព្រមទាំងត្រូវគោរពឲ្យបានម៉ឺងម៉ាត់ នូវច្បាប់ស្ដីពីការងារ ច្បាប់ស្ដីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ និងច្បាប់ បទប្បញ្ញត្តិនានា ដែលពាក់ព័ន្ធ និងផលិតកម្ម អាជីវកម្មរបស់ក្រុមហ៊ុន ។

**ប្រការ ៧ :** ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសចំពោះគូរនឹងប្រការណាមួយដែលបានចែងខាងលើប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

ប្រការ ៨ : អគ្គនាយកឧស្សាហកម្ម នៃក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល រាជធានីភ្នំពេញ និងប្រធានក្រុមហ៊ុន ហ៊្វុយ រ៉ែរប្យូ (ខេមបូឌា) ពិតប្រាកដ ត្រូវអនុវត្តប្រកាសនេះតាមមុខការរៀងៗខ្លួន ។

ប្រការ ៩ : ប្រកាសនេះមានអនុភាពពតតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ស៊ុយ សែម

***

## ៣- នីតិការរដ្ឋមន្ត្រី ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

## ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ ២០០០

### ប្រកាសលេខ ០២១ បទ.ប្រក

### ស្តីពីសេវាស្ថាបនាការ ថែទាំទូរស័ព្ទ ទូរសារ និងទូរលេខ ក្នុងតំបន់ក្រុងភ្នំពេញ និងតំបន់ខេត្ត-ក្រុង

***

### រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការ រៀបចំ និងប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ. ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ ១៩៩៧ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពីប្រៃសណីយ៍ និងទូរគមនាគមន៍

- បានឃើញអនុក្រឹត្យលេខ ៦៦ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញ សេចក្តីសម្រេចលេខ១៥៥ សសរ. ចុះថ្ងៃទី១១-១២-១៩៩១ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពីរោងនានុក្រមគ្រប់គ្រងតម្លៃ
- បានឃើញកំណត់ហេតុអង្គប្រជុំនាថ្ងៃទី១៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការកែប្រែតម្លៃសេវាទូរគមនា-គមន៍
- យោងតាមស្មារតីអង្គប្រជុំថ្ងៃទី ០៣ ខែកុម្ភៈ ឆ្នាំ ២០០០
- យោងតាមស្មារតីអង្គប្រជុំរបស់ថ្នាក់ដឹកនាំក្រសួង ចុះថ្ងៃទី ០៥ ខែមករា ឆ្នាំ ២០០០

**សំរេច**

**ប្រការ ១ :** កំណត់តម្លៃស្ថាបនាការ ថែទាំទូរស័ព្ទ ទូរសារ និងទូរពុម្ព សំរាប់តំបន់ក្រុងភ្នំពេញ និង តំបន់ខេត្ត-ក្រុង ដូចមានចែងក្នុងតារាងភ្ជាប់មកជាមួយនេះ ។

**ប្រការ ២ :** សំភារៈស្ថាបនា និងបរិធានទូរស័ព្ទ ជាបន្ទុករ៉ាប់រង និងជាកម្មសិទ្ធិរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ។

**ប្រការ ៣ :** រាល់ប្រកាសទាំងឡាយណាដែលផ្ទុយពីខ្លឹមសារ នៃប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៤ :** ខុទ្ទកាល័យ អធិការដ្ឋាន គ្រប់នាយកដ្ឋាន និងអង្គភាពក្រោមឱវាទក្រសួង ត្រូវទទួលបន្ទុកតាមតួនាទី ភារៈកិច្ចអនុវត្តតាមប្រកាសនេះឲ្យមានប្រសិទ្ធភាព ។

**ប្រការ ៥ :** ប្រកាសនេះមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

សូ ឃុន

★★★

តារាងភ្ជាប់ប្រកាសលេខ ០២១ បទប្រក.

ចុះថ្ងៃទី ១១-០២-២០០០

## តារាងថ្លៃសេវា
## ស្ថាបនាការ ថែទាំទូរស័ព្ទ ទូរសារ ទូរពុម្ព
## ក្នុងតំបន់ក្រុងភ្នំពេញ និងតំបន់ខេត្ត-ក្រុង
## អនុវត្តចាប់ពីថ្ងៃទី ០១ ខែ មិនា ឆ្នាំ២០០០

***

| ក- ទូរស័ព្ទ ទូរសារ | I- តំបន់ក្រុងភ្នំពេញ | II- តំបន់ខេត្ត-ក្រុង |
|---|---|---|
| **១- ស្ថាបនា-ការទូរស័ព្ទ ទូរសារ** | | |
| ១-១- ស្ថាបនា-ភ្ជាប់បណ្តាញថ្មី | | |
| គិតទាំងបរិធាន និងសម្ភារៈ............... | ១៥០$/គ្រឿង | ១០០$/គ្រឿង |
| ១-២- ប្តូរប្រព័ន្ធ ឬបណ្តាញ (Chang Over).... | ៥០$/គ្រឿង | ២០$/គ្រឿង |
| ១-៣- តម្លើងបរិធានភ្ជាប់បំបែក (Parallel)(1).... | ៣០$/គ្រឿង | ៣០$/គ្រឿង |
| ១-៤- តម្លើងម៉ាស៊ីនទូរសារ (ម៉ាស៊ីនឯកជន).... | ២០$/គ្រឿង | ២០$/គ្រឿង |
| ១-៥- ផ្ទេរទីកន្លែង (ក្នុងអាគារ).................... | ១០$/គ្រឿង | ១០$/គ្រឿង |
| ១-៦- ផ្ទេរអាស័យដ្ឋាន............................. | ៥០$/គ្រឿង | ២០$/គ្រឿង |
| **២- ការផ្តល់លេខទូរស័ព្ទ (២)(៤)(៦)** | | |
| ២-១- ផ្ទេរកម្មសិទ្ធិ "ដាក់ឈ្មោះ" ............... | ៦០$/លេខ | ៥០$/លេខ |
| ២-២- ផ្តល់លេខទូរស័ព្ទប្រភេទ "Reversed Signal" | ៣០$/លេខ | ៣០$/លេខ |
| ២-៣- ផ្តល់លេខទូរស័ព្ទប្រភេទ "Hunting Group" | ២០$/លេខ | ២០$/លេខ |
| ២-៤- ប្តូរលេខទូរស័ព្ទ .......................... | ៥០$/លេខ | ២០$/លេខ |
| **៣- ប្រាក់ធានាតំកល់ទុកសំរាប់ការប្រើប្រាស់ (មង់ម្តង) (៣)** | | |
| ៣-១- សេវាក្នុងប្រទេស ............... | ៦០$/លេខ | គ្មាន |
| ៣-២- សេវាក្នុងប្រទេស និងអន្តរជាតិ ............ | ២០០$/លេខ | ២០០$/លេខ |

**៤- ការស្ថាបនាប្រើប្រាស់បណ្តោះអាសន្ន រយៈបី (៣) ខែខ្ពីបំផុត**

អនុវត្តតម្លៃត្រង់ចំណុច ១.១, ២.២, ២.៣ ស្មើ ៥០ភាគរយ និងចំណុច ៣ ខាងលើ ។

**ខ- ទូរពុម្ព (TELEX) (៥) : ប្រើប្រាស់មជ្ឈមណ្ឌលនៅក្រុងហុងកុង**

★★★

តារាងភ្ជាប់ប្រកាសលេខ ០២១ ឃទប្រក.

ចុះថ្ងៃទី១១ ០២-២០០០

១- តំបន់ក្រុងភ្នំពេញ

១-១- ស្ថាបនាការទូរពុម្ព តម្លៃម៉ៅផ្ដាច់ (ម៉ាស៊ីនឯកជន) ............... ៣៥០$/គ្រឿង

១-២- តម្លើងម៉ាស៊ីនទូរពុម្ព (ម៉ាស៊ីនឯកជន) ............................ ៣០$/គ្រឿង

២- តំបន់ខេត្ត-ក្រុង អនុវត្តតំលៃដោយបេតការណ៍ (Estimate) តាមខេត្ត-ក្រុងនិមួយៗ

២-១- តំលៃបរិបថតំណរ: 2.4 Kbps (4w)

២-២- តំលៃម៉ៅផ្ដាច់ក្នុងក្រុង (ម៉ាស៊ីនឯកជន) .............................. ៣៥០$/គ្រឿង

២-៣- តម្លើងម៉ាស៊ីនទូរពុម្ព (ម៉ាស៊ីនឯកជន)

៣- ប្រាក់ធានាតំកល់ទុកសំរាប់ការប្រើប្រាស់ .......................... ២០០$/គ្រឿង

គ- ថ្លៃជួលសេវាប្រចាំខែ

១- ការប្រើប្រាស់ទូរស័ព្ទ-ទូរសារ

| | តំបន់ក្រុងភ្នំពេញ | តំបន់ខេត្ត-ក្រុង |
|---|---|---|
| ១-១- ជួលជាវនិងថែទាំបណ្ដាញ | ១៣$/លេខ | ១០$/លេខ |
| ១-២- បរិធានភ្ជាប់បំបែក | ២$/លេខ | ២$/លេខ |
| ១-៣- លេខទូរស័ព្ទប្រភេទ "Reversed signal" | ៣$/លេខ | ៣$/លេខ |

២- ការប្រើប្រាស់ទូរពុម្ព

២-១- ជួលជាវនិងថែទាំបណ្ដាញក្រៅប្រទេស ៥៥$/លេខ

២-២- ជួលជាវនិងថែទាំបណ្ដាញក្នុងក្រុង ២៦$/លេខ

២-៣- ជួលជាវនិងថែទាំបណ្ដាញក្នុងប្រទេស ............. ៣៦$/លេខ

៣-ការផ្អាកប្រើប្រាស់បណ្ដោះអាសន្ន សេវាទូរស័ព្ទនិងសេវាទូរពុម្ព

៣-១- អនុញ្ញាតការផ្អាកបណ្ដោះអាសន្នត្រឹមរយៈ ៣ (បី) ខែ គិតថ្លៃ ៥០% នៃថ្លៃជួលជាវប្រចាំខែ។

៣-២- ការបង់ថ្លៃជួលជាវសេវាដែលបានប្រើប្រាស់មិនពេញខែ ត្រូវបានគិតតាមចំនួនថ្លៃប្រើប្រាស់ ក្នុងតំលៃ ១/៣០ ភាគ នៃថ្លៃជួលជាវប្រចាំខែ ។

៤-ការផ្ដល់វិក្កយបត្រលំអិតលើការប្រើប្រាស់សេវា(៧)

-វិក្កយបត្រលំអិត សន្ទនាការទូរស័ព្ទក្នុងក្រុងប្រចាំខែ ................ ៣$ / ច្បាប់

★★★

៥ លក្ខខណ្ឌនៃការផ្គត់ផ្គង់សេវា :

៥-១- ការស្នាបនា-តម្លើងបរិធានភ្ជាប់បំបែក (Parallel) ត្រូវបានអនុញ្ញាតតាមលក្ខខ័ណ្ឌបច្ចេកទេសបានមួយគ្រឿងក្នុងអាគារតែមួយ សំភារៈផ្គត់ផ្គង់ដោយក្រសួង ។

៥-២- លេខទូរស័ព្ទត្រូវបានផ្គត់ផ្គង់ជូនជាកម្មសិទ្ធឯកជន ពុំអាចបំពើសាធារណៈដោយគ្មានច្បាប់អនុញ្ញាត ។

៥-៣- ប្រាក់ធានាតំកល់ទុកត្រូវបានបង់ក្នុងគ្រាស្នាបនាការ និងត្រូវដកបង្វែរជូនអតិថិជនវិញ លុះត្រាណាបានសុំបញ្ឈប់ការប្រើប្រាស់សេវាជាស្ថាពរ និងបានធ្វើការទូទាត់ថ្លៃសេវាគ្រប់ចំនួន ។

៥-៤- ភ្នាក់ងារមានច្បាប់លក់លេខទូរស័ព្ទនៅរាជធានីភ្នំពេញ អាចគិតយកថ្លៃ ៣០ ដុល្លារ (៣០$) និងនៅខេត្តមួយគ្រឿង ១០ ដុល្លារ (១០$) បន្ថែមលើថ្លៃស្នាបនាការគ្រាដំបូង (Installation Fees) ដែលរដ្ឋកំណត់ សំរាប់ការងារសិក្សាទីផ្សារ និងផ្សព្វផ្សាយពាណិជ្ជកម្ម ។

៥-៥- ការស្នាបនាប្រើប្រាស់សេវាទូរពុម្ព (Telex) ជាបណ្តោះអាសន្នពុំត្រូវបានអនុញ្ញាត ។

៥-៦- ការផ្លាស់ប្តូរលេខទូរស័ព្ទ ត្រូវធ្វើការទូទាត់បំណុលថ្លៃសេវាជាមុន ។

៥-៧- វិក្កយបត្រប្រើប្រាស់សេវាត្រូវបានចេញជូនរៀងរាល់ដំណាច់ខែ នៃប្រតិទិន មានទំរង់ជាតារាងសរុបលើប្រភេទសន្ទនាការ ។ អតិថិជនអាចសុំអោយផ្តល់វិក្កយបត្រតាមករណីពិសេសដោយត្រូវបង់ថ្លៃបន្ថែម ។

★★★

រាជធានីភ្នំពេញ,ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ ១៩៩៩

## ប្រកាសលេខ ០២២ មទ.ប្រក

## ស្តីពីថ្លៃសេវាទូរគមនាគមន៍

## និងរូបភាពទូរទស្សន៍ ប្រើប្រាស់ក្នុងប្រទេស និងអន្តរជាតិ

***

## រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការ រៀបចំ និងប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី

- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ០៥ អនក្រ. ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ ១៩៩៧ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពីប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ៦៦ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញ សេចក្តីសម្រេចលេខ១៥៤ សសរ. ចុះថ្ងៃទី១១-១២-១៩៩១ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពីឋានានុក្រមគ្រប់គ្រងតម្លៃ
- បានឃើញកំណត់ហេតុអង្គប្រជុំនាថ្ងៃទី១៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការកែប្រែតម្លៃសេវាទូរគមនា-គមន៍
- យោងតាមស្មារតីអង្គប្រជុំថ្ងៃទី ០៣ ខែកុម្ភៈ ឆ្នាំ ២០០០
- យោងតាមស្មារតីនៃអង្គប្រជុំរបស់ថ្នាក់ដឹកនាំក្រសួង ចុះថ្ងៃទី ០៥ ខែមករា ឆ្នាំ ២០០០

**សំរេច**

**ប្រការ ១ :** កំណត់ថ្លៃសេវាទូរគមនាគមន៍ និងរូបភាពទូរទស្សន៍ សំរាប់ការប្រើប្រាស់ក្នុងប្រទេស និងអន្តរជាតិ ដូចមានចែងក្នុងតារាងថ្លៃសេវាភ្ជាប់មកជាមួយនេះ ។

**ប្រការ ២ :** ប្រកាសទាំងឡាយណាដែលពីមុនមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៣ :** ខុទ្ទកាល័យ អធិការដ្ឋាន គ្រប់នាយកដ្ឋាន និងអង្គភាពក្រោមឱវាទក្រសួង ត្រូវទទួលបន្ទុកតាមតួនាទី ភារកិច្ចអនុវត្តតាមប្រកាសនេះឲ្យមានប្រសិទ្ធភាព ។

**ប្រការ ៤ :** ប្រកាសនេះមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**សូ ឃុន**

★★★

លេខ ០២២ បទប្រក/ .....

**តារាងថ្លៃសេវា**

**គ្នាប់សន្ទនាការទូរស័ព្ទ គមនាគមន៍ព័ត៌មាន**

**និងរូបភាពទូរទស្សន៍ក្នុងប្រទេស និងអន្តរជាតិ**

***

**សេវានិងបណ្តាញរបស់រដ្ឋ**

**តម្លៃអនុវត្តចាប់ពីថ្ងៃទី ០១ ខែមីនា ឆ្នាំ២០០០ វេលាសូន្យម៉ោងតទៅ**

## I- សេវា និង បណ្តាញដែនដី

### ១- ទូរស័ព្ទក្នុងប្រទេស :

១-១- សន្ទនាទូរស័ព្ទក្នុងប្រទេស : គិតជា "សេនសហរដ្ឋ មួយនាទី"

| សេវារដ្ឋ / បណ្តាញទូរស័ព្ទ | ថ្លៃសន្ទនាការទូរស័ព្ទ | | | | |
|---|---|---|---|---|---|
| | សន្ទនាក្នុង | | ភ្នំពេញ-ខេត្ត | ខេត្ត-ភ្នំពេញ | ខេត្ត-ខេត្ត |
| | ភ្នំពេញ | ខេត្ត | | | |
| ក- ហៅក្នុងបណ្តាញរដ្ឋ<br>ចរបេ័ត : D.2,4,7 និង 8 | 1 c | | 15 c | 15c | |
| ខ- ហៅចូលបណ្តាញក្រុមហ៊ុន<br>+ អចល័ត : -CAMSHIN : D.3 | 5c | 2c | 20c | | |
| -CAMINTEL : D.9 | 5c | 5c | 20c | | |
| + ចល័ត : -CAMSHIN : C.011<br>-CamGSM : C.012<br>-CASACOM : C.015<br>-CASACOM : C.016<br>-CAMTEL : C.018 | | 15c | | | |

១-២- សន្ទនាតាមរយៈទូរស័ព្ទការី (OPERATOR ASSISTED) ថ្លៃអប្បបរមាស្មើ ៣នាទីដំបូង និងបន្ថែម ៣នាទីជា បន្តបន្ទាប់

★★★

លេខ ០២២ បទប្រក/ .....

២- <u>សន្ទនាទូរស័ព្ទអន្តរជាតិ</u> : គិតជា "ដុល្លារសហរដ្ឋ មួយនាទី"

| <u>ទិសដៅ</u> | <u>តម្លៃធម្មតា</u> | <u>ថ្ងៃសៅរ៍ និងអាទិត្យ</u> (ពី០០ ម៉ ០០-២៣ម៉៥៩) |
|---|---|---|
| ២-១- ប្រទេសឡាវ វៀតណាម និងថៃឡង់ | ១.៦៨ | ១.៣៥ |
| ២-២- ប្រទេសដទៃទៀតក្នុងទ្វីបអាស៊ី | ១.៨២ | ១.៥៦ |
| ២-៣- បណ្តាញប្រទេសក្នុងទ្វីបដទៃទៀត | ២.០៣ | ១.៦៣ |

២.៤- សន្ទនាតាមរយៈបុគ្គលិកការី (OPERATOR ASSISTED) : គិតថ្លៃអប្បបរមាស្មើ ៣នាទី ដំបូងនៃតម្លៃធម្មតា រួចបន្ថែមមួយនាទីជាបន្តបន្ទាប់

៣- <u>ទូរសារសាធារណៈ</u>

៣-១- ការទទួលនិងការចែកចាយអាស័យដ្ឋាន : គិតជាប្រាក់ "រៀល"

តម្លៃអនុវត្តលើបុគ្គលអ្នកទទួលសារ បើអ្នកផ្ញើរពុំបានបង់ថ្លៃជាមុន

៣-១-១- ការទទួលគិតជាទំព័រ ............ ១០០៛ មួយទំព័រ

៣-១-២- ការចែកចាយអាស័យដ្ឋានក្នុងក្រុងគិតជាច្បាប់ ១.០០០៛ មួយច្បាប់

៣-២- ការបញ្ជូនទូរសារសាធារណៈក្នុងប្រទេស : គិតជា "សេនសហរដ្ឋ មួយនាទី"

| សេវារដ្ឋ / បណ្តាញទូរស័ព្ទ | ថ្លៃបញ្ជូនទូរស័ព្ទសាធារណៈ | | | | |
|---|---|---|---|---|---|
| | ទូរសារក្នុង | | ភ្នំពេញ-ខេត្ត | ខេត្ត-ភ្នំពេញ | ខេត្ត-ខេត្ត |
| | ភ្នំពេញ | ខេត្ត | | | |
| ក- លេខក្នុងបណ្តាញរដ្ឋ អចល័ត : D.2,4,7 និង 8 | 10 c | | 26 c | 25c | |
| ខ- លេខទូរស័ព្ទបណ្តាញក្រុមហ៊ុន + អចល័ត : -CAMSHIN : D.3 | 15c | 12c | 30c | | |
| -CAMINTEL : D.9 | 15c | | 40 c | 25 c | |
| + ចល័ត : -CAMSHIN : C.011<br>-CamGSM : C.012<br>-CASACOM : C.015<br>-CASACOM : C.016<br>-CAMTEL : C.018 | 25c | | | | |

**កំណត់សំគាល់** : ត្រូវបន្ថែមថ្លៃសេវាទទួល និងចែកដល់អាស័យដ្ឋាន បើមានតំរេហ៊ី

★★★

លេខ ០២២ បទ.ប្រក/ .....

៣-៣ ការបញ្ជូនទូរសារអន្តរជាតិ : គិតជា "ដុល្លារសហរដ្ឋ មួយនាទី"

| **ទិសដៅ** | **តម្លៃធម្មតា** |
|---|---|
| ៣-៣-១- ប្រទេសឡាវ វៀតណាម និងថៃឡង់ | ១.៩០ |
| ៣-៣-២- ប្រទេសដទៃទៀតក្នុងទ្វីបអាស៊ី | ២.០៦ |
| ៣-៣-៣- បណ្តាប្រទេសក្នុងទ្វីបដទៃទៀត | ២.៣០ |

**៤- ទូរពុម្ព : ទូរពុម្ពសាធារណៈ និង ទូរលេខ**

| ទិសដៅ | ទូរពុម្ព (គិតជាដុល្លារសហរដ្ឋ/នាទី) | ទូរពុម្ពសាធារណៈ (គិតជាដុល្លារសហរដ្ឋ/ពាក្យ) | ទូរលេខ |
|---|---|---|---|
| ៤-១- ក្នុងប្រទេស | ០.៣០ | ០.៣៥ | ០.០៥ |
| ៤-២- ក្រុងហុងកុង | ១.៩០ | ២.១០ | ០.២៥ |
| ៤-៣- ប្រទេសឡាវ វៀតណាម និងថៃឡង់ | ២.២០ | ២.៥០ | ០.២៨ |
| ៤-៤- ប្រទេសដទៃទៀតក្នុងទ្វីបអាស៊ី | ២.៣៥ | ២.៥៦ | ០.៣០ |
| ៤-៥- ប្រទេសក្នុងទ្វីបដទៃទៀត | ២.៥០ | ២.៧០ | ០.៣២ |

**កំណត់សំគាល់** : ១- ទូរលេខមួយច្បាប់គិតអប្បបរមា ស្មើ ១០ពាក្យ មានតម្លៃ និងអាទិភាពទទួល និងចែកជូនដល់អាស័យដ្ឋាន

២- ទូរពុម្ពសាធារណៈក្នុងប្រទេសត្រូវគិតបន្ថែមសេវាទទួល និងចែកដល់អាស័យដ្ឋាន បើមានសំណើ ។

**៥- ការទទួល និងចែកសារទូរពុម្ពសាធារណៈ** : គិតជាប្រាក់ "រៀល"

តម្លៃអនុវត្តលើបន្ទុកម្ចាស់អ្នកទទួលសារ បើអ្នកផ្ញើពុំបានបង់ថ្លៃជាមុន

៥-១- ការទទួលគិតជាទំព័រ .............................. ១៥០ ៛ មួយទំព័រ

៥-២- ការចែកដល់អាស័យដ្ឋានក្នុងក្រុង .................. ១.០០០ ៛ មួយច្បាប់

**៦- សេវាវិទ្យុទូរស័ព្ទក្នុងប្រទេស** : សន្ទនាការគិតជា "សេនសហរដ្ឋ" ៣នាទីដំបូង និង៣នាទីបន្តបន្ទាប់ ។

៦-១- សន្ទនានៅផ្ទាល់តាមស្ថានីយវិទ្យុ : គ្រប់ការិយាល័យប្រៃសណីយ៍និងទូរគមនាគមន៍

សន្ទនារវាងខេត្ត-ក្រុង ............................ ៥០c/៣នាទី

៦-២- សន្ទនាពាក់កណ្ដាលស្វ័យប្រវត្តិ ហៅលេខ code " 094 "

សន្ទនារវាងខេត្ត-ក្រុង ........................... ៥០c/៣នាទី

៦-៣- លិខិតអញ្ជើញអ្នកសន្ទនា (គិតជាប្រាក់រៀល) ........................ ១.០០០រ/ច្បាប់

★★★

លេខ ០២២ បទ-ប្រក/ .....

៧- <u>សេវា</u> : E-mail សកលតាមរយៈ តាមរយៈ Intenet " Camnet"

៧-១- ការប្រើប្រាស់ Internet 1$/10 នាទី

៧-២- ការបញ្ជូន E-mail : 1$/Message (បើលើសពី១០នាទី គិតប្រាក់តាម ៧.១)

៧-៣- ការប្រើប្រាស់ Computer

៧-៣-១- សរសេរអត្ថបទ ១$/ម៉ោង

៧-៣-២- Printer 500 រ/ទំព័រ

៨- <u>សេវាបញ្ជូនរូបភាពទូរទស្សន៍អន្តរជាតិ</u> : តាមរយៈប្រព័ន្ធ Interlsat

ថ្លៃគិតត្រឹមពាក់កណ្ដាលផ្លូវពីស្ថានីយ៍ **Studio** ដល់ ផ្កាយអវកាស

៨-១- រយៈពេលអប្បបរមា ១០នាទីដំបូង ............................ ៣៥០$/១០នាទី

៨-២- មួយនាទីជាបន្តបន្ទាប់ ......................................... ២០$/នាទី

៨-៣- ការធ្វើតេស្តផ្លូវអាកាសជាបន្ទុកនៃប្រទេស

ស្ថានីយ៍ Studio ទទួល (Receiving Station ) ជាអ្នករ៉ាប់រង ។

## II- សេវាវិទ្យុឆ្នេរសមុទ្រ :

### ៩- <u>តំបន់សេវាក្រុងព្រះសីហនុ និងផ្ទៃសមុទ្រខាងត្បូង</u>

៩-១- សេវាស្ថានីយ៍ឆ្នេរ "XUK" គិតជា

| ប្រភេទសេវា | សេវាស្ថានីយ៍ | | | កំណត់សំគាល់ |
|---|---|---|---|---|
| | HF | MF | VHF | |

៩-១-១- វិទ្យុទូរលេខ : Radio telegrams ៥c/ពាក្យ

៩-១-២- លិខិតវិទ្យុឆ្នេរ : Radio maritime letters គិតបន្ថែមថ្លៃសេវាប្រៃសណីយ៍ ទូរលេខបញ្ជូនបន្តតាមប្រៃសណីយ៍

៩-១-៣- វិទ្យុទូរស័ព្ទ : ២.១៥$/នាទី 30c/នាទី ៣០c/នាទី ស្វ័យប្រវត្តិ និងពាក់កណ្ដាលស្វ័យប្រវត្តិ Radio telephone

៩-១-៤- វិទ្យុទូរពុម្ព : Radiotelex ២.២០$/នាទី34c/នាទី ៣៤c/នាទី

ស្វ័យប្រវត្តិ និងពាក់កណ្ដាលស្វ័យប្រវត្តិ

៩-១-៥- ទូរលេខវិទ្យុទូរពុម្ព : Radiotelexogram គិតបន្ថែមថ្លៃសេវាទូរពុម្ព

ទូរលេខបញ្ជូនបន្តតាមទូរពុម្ព

★★★

លេខ ០២២ ពទ-ប្រក/ .....

៩-១-៦- ការបញ្ជូន-ទទួលសេចក្ដីប្រកាសអាសន្ន ពុំគិតព្រោះជាមុខងារស្ថាប័នពាក់ព័ន្ធ

៩-១-៧- ការឆ្លើយឆ្លងពត៌មានឧតុនិយម

៩-២- សេវាពាក់កណ្ដាលស្វ័យប្រវត្តិគិតអប្បបរមា ៣នាទី និងមួយនាទីបន្ថែមជាបន្តបន្ទាប់ ។

៩-៣- ចរន្តសេវា : ស្ថានីយ៍នាវាដែលស្នើសុំសេវា ជាអ្នកបង់ថ្លៃសេវា តំលៃត្រូវគិត :

៩-៣-១- ស្ថានីយ៍នាវាឆ្លងស្ថានីយ៍ឆ្នេរទៅអន្តរជាតិ សេវាអន្តរជាតិ + សេវាស្ថានីយ៍ឆ្នេរ

៩-៣-២- ស្ថានីយ៍នាវាឆ្លងស្ថានីយ៍ឆ្នេរទៅស្ថានីយ៍នាវា សេវាស្ថានីយ៍ឆ្នេរ x ២ ដង

៩-៣-៣- ស្ថានីយ៍នាវាឆ្លងស្ថានីយ៍ឆ្នេរទៅបណ្ដាញក្នុងប្រទេស សេវាស្ថានីយ៍ឆ្នេរ + សេវាក្នុងប្រទេស

៩-៣-៤- ស្ថានីយ៍នាវាឆ្លងស្ថានីយ៍ឆ្នេរទៅស្ថានីយ៍នាវាតាមស្ថានីយ៍ឆ្នេរប្រទេសផ្សេង :

សេវាអន្តរជាតិ + សេវាស្ថានីយ៍ឆ្នេរ

បរទេស + ស្ថានីយ៍ឆ្នេរ

៩-៤- ស្ថានីយ៍នាវាអាចគិតយកថ្លៃសេវាបន្ថែមលើថ្លៃខាងលើសំរាប់ចរន្តសេវាសាធារណៈ ដោយមានការផ្សព្វផ្សាយជាមុន និងទៀងទាត់ ។

៩-៥ ស្ថានីយ៍នាវាដែលពុំមានអាជ្ញាប័ណ្ណប្រើប្រាស់ស្ថានីយ៍វិទ្យុ និងពុំមានអាជ្ញាធរទូទាត់គណនីប្រើប្រាស់សេវា ពុំមានសិទ្ធិសុំសេវាស្ថានីយ៍ឆ្នេរ ។

៩-៦ ស្ថានីយ៍ឆ្នេរត្រូវធ្វើការទូទាត់គណនីសេវារបស់ស្ថានីយ៍នាវា ដោយផ្ទាល់ជាមួយអាជ្ញាធរទូទាត់គណនី (Accounting Authority) រៀងរាល់ដំណាច់ត្រីមាសប្រតិទិនមួយៗ ។

១០- **គមនាគមន៍ព័ត៌មានមាននាវាចរណ៍តាមរយៈ** : INMARSAT ជាប្រភេទសេវាអន្តរជាតិ

១០.១ សន្ទនាការចេញពីបណ្ដាញក្នុងប្រទេស (IDD).........................៥$/នាទី

១០.២ សន្ទនាការចេញពីស្ថានីយ៍នាវា តំលៃសរុប :

១០.២.១ សេវាស្ថានីយ៍ឆ្នេរ

១០.២.២ សេវាក្នុងប្រទេស

១០.២.៣ សេវា INMARSAT

**កំណត់សំគាល់** : សន្ទនាការ INMARSAT អាចភ្ជាប់តាមរយៈមាត់ច្រកអន្តរជាតិដោយប្រើ Codes :

១- Atlantic Occean Region 'AOR - West" : 871

២- Pacific Ocean Region 'POR " : 872

៣- Indian Ocean Region 'IOR" : 873

៤- និង Atlantic Occean Region 'AOR - East" : 874

★★★